GC LiFE

# អត្ថប្រយោជន៍
# បន្ថែមការការពារ



## លក្ខណៈនៃផលិតផល

| | |
|---|---|
| អាយុអ្នកត្រូវបានធានារ៉ាប់រង | 1 - 60ឆ្នាំ |
| រយៈពេលធានារ៉ាប់រង | 5 - 30ឆ្នាំ |
| ទឹកប្រាក់ត្រូវបានធានា | ចាប់ពី $5,000 ឡើង |

## អត្ថប្រយោជន៍ធានារ៉ាប់រង

### ជម្រើសទី១

ករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍



ម្ចាស់បណ្ណសន្យារ៉ាប់រង



អ្នកត្រូវបានធានារ៉ាប់រង

១០០% នៃទឹកប្រាក់ត្រូវបានធានានឹងត្រូវផ្តល់ជូន ក្នុងករណីម្ចាស់បណ្ណសន្យារ៉ាប់រង និង/ឬ អ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬពិការភាព ទាំងស្រុង និងជាអចិន្ត្រៃយ៍។





# ជម្រើសទី២

## ករណីមរណភាព ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ឬជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់



ម្ចាស់បណ្ណសន្យារ៉ាប់រង



អ្នកត្រូវបានធានារ៉ាប់រង

១០០% នៃទឹកប្រាក់ត្រូវបានធានានឹងត្រូវផ្តល់ជូន ក្នុងករណីម្ចាស់បណ្ណសន្យារ៉ាប់រង និង/ឬ អ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ឬធ្វើរោគវិនិច្ឆ័យរកឃើញ/ការវះកាត់ជាក់ស្តែងនូវជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់ណាមួយដូចបានចែងក្នុងខ និងលក្ខខណ្ឌនៃបណ្ណសន្យារ៉ាប់រង។



ការពារអ្នក ក្រុមគ្រួសារអ្នក

និងអនាគតរបស់អ្នក



ចំណាំ៖ ខ្លឹមសារក្នុងខិត្តប័ណ្ណផ្សព្វផ្សាយនេះគឺជាការពណ៌នាដោយសង្ខេប។ សម្រាប់ព័ត៌មានលម្អិតនៃការធានារ៉ាប់រង រួមមានអត្ថប្រយោជន៍ធានារ៉ាប់រង ករណីមិនធានា និងលក្ខខណ្ឌនៃការបញ្ចប់កិច្ចសន្យា សូមអានខ និងលក្ខខណ្ឌធានារ៉ាប់រង។

# I ករណីមិនធានា

### ១. មរណភាព

ករណីផ្សេងៗដូចបានចែងក្នុង "ករណីមិនធានា" នៃផលិតផលមូលដ្ឋាន។

### ២. ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍

ករណីផ្សេងៗដូចបានចែងក្នុង "ករណីមិនធានា" នៃផលិតផលមូលដ្ឋាន។

### ៣. ជំងឺធ្ងន់ធ្ងរ

(១) ជំងឺដែលបណ្ដាលមកពីជំងឺអេដស៍ ភាពស្មុគស្មាញទាក់ទងនឹងជំងឺអេដស៍ ឬការបង្ករោគដោយវីរុសហ៊ីវ (HIV)។

(២) ស្ថានភាពដែលមានពីមុនស្រាប់ មុនកាលបរិច្ឆេទដែលអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះមានសុពលភាព ឬកាលបរិច្ឆេទនៃការបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញដោយយកកាលបរិច្ឆេទចុងក្រោយគេ។ស្ថានភាពដែលមានពីមុនស្រាប់ មានន័យថាជាជំងឺដែលអ្នកត្រូវបានធានារ៉ាប់រងបានដឹងច្បាស់ លុះត្រាតែស្ថានភាពទាំងនោះត្រូវបានប្រកាសមកកាន់ក្រុមហ៊ុន និងទទួលយកដោយក្រុមហ៊ុន។ អ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងអាចត្រូវបានចាត់ទុកថាបានដឹងច្បាស់អំពីស្ថានភាពដែលមានពីមុនស្រាប់ ប្រសិនបើមានស្ថានភាពណាមួយដូចបានចែងខាងក្រោម៖

- ក. អ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងបានទទួល ឬកំពុងទទួលការព្យាបាល
- ខ. យោបល់វេជ្ជសាស្ត្រ ការធ្វើរោគវិនិច្ឆ័យ ការថែទាំ ឬការព្យាបាលផ្នែកវេជ្ជសាស្ត្រត្រូវបានណែនាំ
- គ. មានរោគសញ្ញាច្បាស់ និងជាក់លាក់ត្រូវបានបង្ហាញ
- ឃ. វត្តមាននៃស្ថានភាពនោះអាចមើលឃើញដោយបុគ្គលធម្មតាក្នុងកាលៈទេសៈណាមួយ។

(៣) ការប៉ុនប៉ងធ្វើអត្តឃាត ឬធ្វើឲ្យរបួសខ្លួនឯង ទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ។

(៤) អ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬការប្រើប្រាស់ថ្នាំណាមួយ លើកលែងតែស្ថិតក្រោមការណែនាំរបស់គ្រូពេទ្យដែលមានអាជ្ញាបណ្ណត្រឹមត្រូវ។

(៥) ជំងឺធ្ងន់ធ្ងរទាំងអស់ដែលមានស្រាប់ ឬធ្វើរោគវិនិច្ឆ័យរកឃើញក្នុងរយៈពេលរង់ចាំដោយរាប់បញ្ចូលទាំងជំងឺធ្ងន់ធ្ងរកម្រិតដំបូង ដែលត្រូវបានរកឃើញពេលធ្វើរោគវិនិច្ឆ័យដំបូងក្នុងរយៈពេលរង់ចាំ ហើយវិវត្តទៅជាជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់បន្ទាប់ពីរយៈពេលរង់ចាំត្រូវបានផុតកំណត់។

(៦) សង្គ្រាម (មិនថាបានប្រកាស ឬមិនបានប្រកាស) ការឈ្លានពាន សកម្មភាពលុកលុយរបស់សត្រូវបរទេស សង្គ្រាមស៊ីវិល បដិវត្តន៍ ចលនាបះបោរ ចលាចលស៊ីវិល ការធ្វើកុបកម្ម ការធ្វើកូដកម្ម ការបះបោរប្រឆាំងនឹងរដ្ឋាភិបាល និងអំពើភេរវកម្ម។

(៧) ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬការប៉ុនប៉ងក្នុងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដោយម្ចាស់បណ្ណសន្យារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល។ អ្នកទទួលផលដែលមិនបានចូលរួមពាក់ព័ន្ធក្នុងសកម្មភាពបទល្មើសព្រហ្មទណ្ឌដែលបានរៀបរាប់ខាងលើ នឹងនៅតែមានសិទ្ធិទទួលបានអត្ថប្រយោជន៍របស់ពួកគេដដែល។

(៨) ប្រសិនបើមានផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលពីការសារធាតុវិទ្យុសកម្មដែលកើតឡើងពីឥន្ធនៈ អាវុធ កាកសំណល់ ឬការកែច្នៃ។

(៩) ការធ្វើដំណើរចូល ការចាកចេញ ការធ្វើប្រតិបត្តិការបញ្ជា ការធ្វើប្រតិបត្តិការជួសជុលថែទាំ ឬត្រូវបានដឹកជញ្ជូនដោយយានឬមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាសនានា លើកលែងតែក្នុងករណីអ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងគឺជាអ្នកដំណើរបង់ប្រាក់ធម្មតា ឬអ្នកបម្រើការលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ពាណិជ្ជមួយ ដែលធ្វើប្រតិបត្តិការជាទៀងទាត់តាមកាលវិភាគ និងតាមគន្លងផ្លូវដឹកជញ្ជូនអ្នកដំណើរផ្លូវអាកាសដែលបានកំណត់ជាមុនរបស់ក្រុមហ៊ុន។

(១០) ការចូលរួមក្នុងសកម្មភាពកីឡាគ្រោះថ្នាក់រួមមាន តែមិនកំណត់ត្រឹមការជ្រមុជទឹក ការឡើងភ្នំ ការលោតឆ័ត្រយោង ឬការប្រណាំងល្បឿនលឿនណាមួយ ឬសកម្មភាពកីឡាអាជីព។